ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមហ៊ុន ហ្គ្រេន ធ្វីន អ៊ិនធើណេសិនណាល
(ខេមបូឌា) ភីអិលស៊ី

*ថ្ងៃពុធ ១០ រោច ខែមាឃ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦*
*រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២៣*

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពីការពន្យារពេលក្នុងការបង្ហាញរបាយការណ៍ប្រចាំត្រីមាសទី៤ ឆ្នាំ២០២២
## របស់ក្រុមហ៊ុន ហ្គ្រេន ធ្វីន អ៊ិនធើណេសិនណាល(ខេមបូឌា) ភីអិលស៊ី

ក្រុមហ៊ុន ហ្គ្រេន ធ្វីន អ៊ិនធើណេសិនណាល (ខេមបូឌា) ភីអិលស៊ី ("**ក្រុមហ៊ុន**") មានកិត្តិយសសូមជម្រាបជូនដំណឹងដល់វិនិយោគិន និងសាធារណជនទាំងអស់ មេត្តាជ្រាបថា៖ ដោយសារមូលហេតុដូចមានរៀបរាប់ខាងក្រោមនេះ ក្រុមហ៊ុនសូមពន្យាពេលបង្ហាញជូនរបាយការណ៍ប្រចាំត្រីមាសទី៤ ឆ្នាំ២០២២ និងផ្តល់ជូនរបាយការណ៍ប្រចាំត្រីមាសទី៤ ឆ្នាំ២០២២ នេះ ជូនវិនិយោគិន និងសាធារណជន យ៉ាងយូរបំផុតត្រឹមថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២៣ ៖

១- ក្រុមហ៊ុនត្រូវរៀបចំស្តុកវត្ថុធាតុដើមឡើងវិញទៅតាមប្រភេទទំនិញ (MPO) នីមួយៗ គិតរហូតដល់ឆ្នាំ២០២២ ដែលត្រូវបែងចែកជា ការលាងឃ្លាំង (Clear Stock) ឬ ត្រូវប្រើប្រាស់បន្តលើការបញ្ជាទិញបន្តបន្ទាប់ទៀត ដែលក្រុមហ៊ុនបានចំណាយពេលវេលាច្រើនលើកិច្ចការពង្រឹងបន្ថែមលើការគ្រប់គ្រងស្តុក និងកិច្ចការលម្អិតផ្ទៀងផ្ទាត់ប្រភេទទំនិញនីមួយៗទាំងអស់ជាមួយនឹងបញ្ជីនេះ។

២- ក្នុងអំឡុងពេលនៃការផ្ទៀងផ្ទាត់បញ្ជីនេះ ស្របពេលគណៈគ្រប់គ្រងក្រុមហ៊ុនដែលទទួលបន្ទុកការងារនេះ បានឈប់សម្រាកក្នុងពិធីបុណ្យចូលឆ្នាំចិនចំនួន ០២ (ពីរ) សប្តាហ៍ ដែលធ្វើអោយក្រុមហ៊ុនមិនអាចបិទបញ្ជីគណនេយ្យទាន់ពេល សម្រាប់ដំណើរការត្រួតពិនិត្យរបាយការណ៍ហិរញ្ញវត្ថុសង្ខេបក្នុងគ្រាដោយក្រុមហ៊ុនសវនកម្មឯករាជ្យរបស់ក្រុមហ៊ុន។

អាស្រ័យដូចមានជម្រាបជូនខាងលើ សូមវិនិយោគិន និងសាធារណជន ទទួលជ្រាបជាព័ត៌មាន។

ព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុន ហ្គ្រេន ធ្វីន អ៊ិនធើណេសិនណាល (ខេមបូឌា) ភីអិលស៊ី GRAND TWINS INTERNATIONAL KINGDOM OF CAMBODIA

**ក្រុមហ៊ុនហ្គ្រេន ធ្វីន អ៊ិនធើណេសិនណាល (ខេមបូឌា) ភីអិលស៊ី**

ទីស្នាក់ការ: ភូមិត្រពាំងពោធិ៍សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ:២៣ ៨៩០ ៣២៥(៨៥៥) /ទូរសារ :២៣ ៨៩០ ៣២៦(៨៥៥) / គេហទំព័រ : www.Grandtwins.com.kh/អ៊ីម៉ែល : vuthy.phuong@qmico.com